**Luke 1:26-38 ការប្រកាសអំពីកំណើតព្រះយេស៊ូវ**

26ប្រាំមួយខែក្រោយមក ព្រះបានចាត់ទេវតាកាព្រីយ៉ែល ឲ្យទៅភូមិមួយឈ្មោះណាសារ៉ែត
ក្នុងស្រុកកាលីឡេ 27ដើម្បីជួបនឹងស្ត្រីព្រហ្មចារីម្នាក់
ដែលជាគូដណ្ដឹងរបស់បុរសម្នាក់ឈ្មោះយ៉ូសែប ជាពូជព្រះបាទដាវីឌ
ហើយស្ត្រីព្រហ្មចារីនោះឈ្មោះម៉ារា។ 28ទេវតាក៏ចូលមកជួបនាង ពោលថា៖
«ជម្រាបសួរនាង ឱនាងដែលប្រកបដោយព្រះគុណអើយ!
ព្រះអម្ចាស់គង់នៅជាមួយនាង»។ 29ប៉ុន្ដែ
នាងមានចិត្តងឿងឆ្ងល់យ៉ាងខ្លាំងដោយឮពាក្យនោះ
ហើយរិះគិតក្នុងចិត្តពីពាក្យជម្រាបសួរនេះមានន័យដូចម្ដេច។ 30ទេវតាពោលទៅនាងថា៖
«កុំខ្លាចអី ម៉ារាអើយ ដ្បិតព្រះគាប់ព្រះហឫទ័យនឹងនាងហើយ។ 31មើល៍! នាងនឹងមានគភ៌
ប្រសូតបានបុត្រាមួយ ហើយនាងត្រូវថ្វាយព្រះនាមថា "យេស៊ូវ"។
32បុត្រនោះនឹងបានជាធំឧត្ដម ហើយគេនឹងហៅទ្រង់ថា "ព្រះរាជបុត្រានៃព្រះដ៏ខ្ពស់បំផុត"
ហើយព្រះអម្ចាស់ដ៏ជាព្រះ នឹងប្រទានរាជ្យបល្ល័ង្ករបស់ព្រះបាទដាវីឌ
ជាបុព្វបុរសរបស់ព្រះអង្គថ្វាយដល់ព្រះអង្គ។
33ព្រះអង្គនឹងសោយរាជ្យលើពូកវង្សរបស់យ៉ាកុបអស់កល្បជានិច្ច
ហើយរាជ្យរបស់ព្រះអង្គនឹងមិនផុតឡើយ» 34ម៉ារាសួរទៅទេវតាថា៖
«តើធ្វើដូចម្ដេចឲ្យការនេះសម្រេចទៅបាន បើខ្ញុំនៅក្រមុំព្រហ្មចារីដូច្នេះ?»
35ទេវតាក៏ឆ្លើយទៅនាងថា៖ «ព្រះវិញ្ញាណបរិសុទ្ធនឹងយាងមកសណ្ឋិតលើនាង
ហើយព្រះចេស្ដានៃព្រះដ៏ខ្ពស់បំផុតនឹងគ្របបាំងនាងដោយស្រមោល ហេតុនេះ
បុត្រដែលនឹងប្រសូតមកនោះ ជាបុត្របរិសុទ្ធ គេនឹងហៅទ្រង់ថា "ព្រះរាជបុត្រានៃព្រះ"។
36មើល៍! អេលីសាបិត ជាញាតិរបស់នាងក៏មានផ្ទៃពោះជាកូនប្រុស
ក្នុងកាលដែលនាងមានវ័យចាស់ហើយដែរ នាងមានផ្ទៃពោះប្រាំមួយខែហើយ
គឺអ្នកដែលគេបានហៅថាជាស្ត្រីអារ។ 37ដ្បិតគ្មានការអ្វីដែលព្រះធ្វើពុំបាននោះឡើយ»។

38ម៉ារាពោលថា៖ «មើល៍! ខ្ញុំនេះជាអ្នកបម្រើរបស់ព្រះអម្ចាស់
សូមឲ្យបានសម្រេចតាមពាក្យរបស់លោកចុះ!»។ បន្ទាប់មក ទេវតាក៏ចេញពីនាងទៅ។

**Matthew 1:18-25 កំណើតរបស់ព្រះយេស៊ូវគ្រីស្ទ**

18រីឯកំណើតរបស់ព្រះយេស៊ូវគ្រីស្ទបានកើតឡើងយ៉ាងដូច្នេះ គឺពេលនាងម៉ារា
មាតាព្រះអង្គបានភ្ជាប់ពាក្យជាមួយយ៉ូសែប មុនពេលអ្នកទាំងពីររួមរស់នៅជាមួយគ្នា
នាងមានគភ៌ដោយព្រះវិញ្ញាណបរិសុទ្ធរួចទៅហើយ។ 19យ៉ូសែប
ប្ដីរបស់នាងជាមនុស្សសុចរិត លោកមិនចង់ធ្វើឲ្យនាងអាម៉ាស់ឡើយ
គឺលោកសម្រេចចិត្តថានឹងលែងនាងដោយសម្ងាត់វិញ។ 20ប៉ុន្តែ
ពេលលោកកំពុងគិតដូច្នេះ
ស្រាប់តែមានទេវតាមួយរូបរបស់ព្រះអម្ចាស់បានលេចមកប្រាប់លោកក្នុងយល់សប្ដិថា៖
«យ៉ូសែប ជាពូជពង្សព្រះបាទដាវីឌអើយ
កុំខ្លាចនឹងយកនាងម៉ារាមកធ្វើជាប្រពន្ធរបស់អ្នកឡើយ
ដ្បិតបុត្រដែលមកចាប់កំណើតក្នុងផ្ទៃនាង គឺមកពីព្រះវិញ្ញាណបរិសុទ្ធទេ។
21នាងនឹងប្រសូតបានបុត្រាមួយ ហើយលោកត្រូវថ្វាយព្រះនាមបុត្រនោះថា "យេស៊ូវ"
ព្រោះបុត្រនោះនឹងសង្គ្រោះប្រជារាស្ត្ររបស់ព្រះអង្គឲ្យរួចពីបាបរបស់គេ»។
22ការទាំងនោះកើតមក
ដើម្បីសម្រេចសេចក្ដីដែលព្រះអម្ចាស់មានព្រះបន្ទូលតាមរយៈហោរាថា៖
23«មើល៍! នាងព្រហ្មចារីនឹងមានគភ៌
ប្រសូតបានបុត្រាមួយ ហើយគេនឹងថ្វាយ
ព្រះនាមបុត្រនោះថា "អេម៉ាញូអែល"»
មានន័យថា «ព្រះគង់ជាមួយយើង»។
24ពេលយ៉ូសែបភ្ញាក់ពីដេកឡើង
លោកក៏ធ្វើតាមពាក្យដែលទេវតារបស់ព្រះអម្ចាស់បានបង្គាប់
គឺលោកបានយកនាងធ្វើជាប្រពន្ធ 25តែមិនបានរួមរស់ជាមួយនាងទេ
រហូតទាល់តែនាងប្រសូតបុត្រ[ច្បងមក] ហើយលោកថ្វាយព្រះនាមបុត្រនោះថា
«យេស៊ូវ»។

**Luke 2:1-7 កំណើតព្រះយេស៊ូវ**

1នៅគ្រានោះ សេសារ-អូគូស្ទ បានចេញព្រះរាជឱង្ការមួយច្បាប់
ឲ្យមនុស្សទាំងអស់ដែលនៅផែនដីបានចុះបញ្ជី។ 2ការចុះបញ្ជីមុនដំបូងនេះ
ធ្វើឡើងនៅពេលលោកគីរេនាសធ្វើជាទេសាភិបាលនៅស្រុកស៊ីរី។
3មនុស្សទាំងអស់ធ្វើដំណើរទៅស្រុកកំណើតរៀងៗខ្លួន ដើម្បីចុះបញ្ជី។ 4រីឯយ៉ូសែប
ក៏ធ្វើដំណើរពីភូមិណាសារ៉ែត ស្រុកកាលីឡេ ឡើងទៅស្រុកយូដា
ដល់ក្រុងរបស់ព្រះបាទដាវីឌ ឈ្មោះបេថ្លេហិម ព្រោះគាត់ជារាជវង្ស
និងជាព្រះញាតិព្រះបាទដាវីឌ 5ដើម្បីចុះបញ្ជីជាមួយម៉ារា ជាគូដណ្ដឹងដែលមានគភ៌នោះ។
6ពេលអ្នកទាំងពីរកំពុងនៅទីនោះ វេលាដែលនាងត្រូវប្រសូតក៏មកដល់។
7នាងប្រសូតបានបុត្រាច្បងមក ហើយរុំបុត្រនោះនឹងសំពត់ រួចដាក់ឲ្យផ្ទំក្នុងស្នូកសត្វ
ព្រោះក្នុងផ្ទះសំណាក់គ្មានកន្លែងសម្រាប់ពួកគេទេ។

Luke 2:8-20 ទេវតាប្រកាសអំពីកំណើតព្រះយេស៊ូវប្រាប់ពួកគង្វាល
8នៅស្រុកនោះ ពេលយប់មានពួកគង្វាលដែលចាំយាម
រក្សាហ្វូងចៀមរបស់ខ្លួននៅតាមទីវាល។ 9ពេលនោះ
មានទេវតារបស់ព្រះអម្ចាស់មួយរូបមកឈរជិតគេ
ហើយសិរីល្អរបស់ព្រះអម្ចាស់ក៏ភ្លឺឆ្វាត់ជុំវិញគេ ធ្វើឲ្យគេភ័យខ្លាចជាខ្លាំង។ 10ប៉ុន្ដែ
ទេវតាពោលទៅគេថា៖ «កុំខ្លាចអី ដ្បិតមើល៍! ខ្ញុំមកប្រាប់ដំណឹងល្អដល់អ្នករាល់គ្នា
ពីអំណរយ៉ាងអស្ចារ្យសម្រាប់មនុស្សទាំងអស់ 11ដ្បិតនៅថ្ងៃនេះ មានព្រះសង្គ្រោះមួយអង្គ
ប្រសូតដល់អ្នករាល់គ្នានៅក្រុងព្រះបាទដាវីឌ គឺព្រះគ្រីស្ទជាព្រះអម្ចាស់។ 12
នេះជាទីសម្គាល់ដល់អ្នករាល់គ្នា គឺអ្នករាល់គ្នានឹងឃើញព្រះឱរសមួយ រុំនឹងសំពត់
ផ្ដេកនៅក្នុងស្នូកសត្វ»។ 13រំពេចនោះ មានពួកពលបរិវារកកកុញពីស្ថានសួគ៌
នៅជាមួយទេវតានោះ ហើយពោលសរសើរដល់ព្រះថា៖
14«សូមលើកតម្កើងសិរីល្អដល់ព្រះដែលគង់នៅស្ថានដ៏ខ្ពស់បំផុត ហើយនៅផែនដី
សូមឲ្យបានប្រកបដោយសេចក្ដីសុខសាន្ដ ដល់អស់អ្នកដែលព្រះអង្គគាប់ព្រះហឫទ័យ!»។
15កាលពួកទេវតាបានចេញពីពួកគេ ត្រឡប់ទៅស្ថានសួគ៌វិញហើយ
នោះពួកគង្វាលនិយាយគ្នាថា៖ «ទៅយើងនាំគ្នាទៅបេថ្លេហិម
ហើយមើលហេតុការណ៍ដែលបានកើតឡើងនោះ ដូចព្រះអម្ចាស់បានប្រាប់ឲ្យយើងដឹង»។
16ដូច្នេះ គេក៏ទៅជាប្រញាប់ ឃើញម៉ារា និងយ៉ូសែប
ព្រមទាំងព្រះឱរសផ្ទំនៅក្នុងស្នូកសត្វ។ 17កាលបានឃើញហើយ
គេក៏រៀបរាប់អំពីសេចក្ដីដែលទេវតាបានប្រាប់អំពីព្រះឱរសនេះ
18ហើយអស់អ្នកដែលបានឮ ក៏មានសេចក្ដីអស្ចារ្យនឹងពាក្យដែលពួកគង្វាលបានប្រាប់។
19ប៉ុន្ដែ ម៉ារារក្សារឿងទាំងនោះ ទាំងត្រិះរិះពិចារណានៅតែក្នុងចិត្តវិញ។
20ឯពួកគង្វាលក៏វិលត្រឡប់ទៅវិញ ទាំងថ្វាយសិរីល្អ ហើយសរសើរតម្កើងដល់ព្រះ
ដោយព្រោះគ្រប់ទាំងការដែលគេបានឮ ហើយឃើញ ដូចជាទេវតាបានប្រាប់។

**Matthew 2:1-12 ពួកហោរមកថ្វាយបង្គំព្រះឱរសយេស៊ូវ**

1ពេលព្រះយេស៊ូវប្រសូតនៅភូមិបេថ្លេហិម ស្រុកយូដា ក្នុងរាជ្យព្រះបាទហេរ៉ូឌ
មានពួកហោរពីទិសខាងកើតធ្វើដំណើរមកក្រុងយេរូសាឡិម សួរថា៖
2«តើបុត្រដែលបានប្រសូតមកជាស្តេចសាសន៍យូដាទ្រង់គង់នៅឯណា?
ព្រោះយើងបានឃើញផ្កាយរបស់ព្រះអង្គពីទិសខាងកើត
ហើយយើងមកថ្វាយបង្គំព្រះអង្គ»។
3កាលព្រះបាទហេរ៉ូឌបានឮដូច្នេះ ទ្រង់មានព្រះហឫទ័យរន្ធត់ជាខ្លាំង
ហើយពួកអ្នកដែលនៅជាមួយព្រះអង្គក្នុងក្រុងយេរូសាឡិមក៏រន្ធត់ចិត្តដែរ។
4ក្រោយពីបានហៅពួកសង្គ្រាជ និងពួកអាចារ្យរបស់បណ្ដាជនមកជួបជុំគ្នាហើយ
ទ្រង់ក៏សាកសួរពួកគេពីកន្លែងដែលព្រះគ្រីស្ទប្រសូត។ 5គេទូលស្តេចថា៖
«នៅភូមិបេថ្លេហិមក្នុងស្រុកយូដា ដ្បិតហោរាបានចែងសេចក្ដីទុកមកដូច្នេះថា
6"ឯឯង បេថ្លេហិម ស្រុកយូដាអើយ! ឯងមិនមែនតូចជាងគេក្នុងចំណោម
ពួកមេដឹកនាំនៅស្រុកយូដាទេ
ដ្បិតនឹងមានមេដឹកនាំម្នាក់កើតចេញពីឯង អ្នកនោះនឹងឃ្វាលអ៊ីស្រាអែល
ជាប្រជារាស្ត្ររបស់យើង"» ។
7ពេលនោះ ព្រះបាទហេរ៉ូឌក៏ហៅពួកហោរនោះមកដោយសម្ងាត់
ហើយសាកសួរអ្នកទាំងនោះពីពេលវេលាជាក់លាក់ ដែលផ្កាយនោះបានលេចមក
8រួចទ្រង់ចាត់ពួកហោរទាំងនោះឲ្យទៅភូមិបេថ្លេហិម ដោយត្រាស់បង្គាប់ថា៖
«ចូរអស់លោកទៅចុះ ហើយស៊ើបសួរពីកូនតូចនោះឲ្យច្បាស់លាស់ ពេលឃើញហើយ
ត្រូវមកប្រាប់យើងវិញ ដើម្បីឲ្យយើងបានទៅថ្វាយបង្គំដែរ»។
9ក្រោយពីបានទទួលការត្រាស់បង្គាប់របស់ស្តេចហើយ គេក៏នាំគ្នាចេញទៅ ពេលនោះ
ផ្កាយដែលគេបានឃើញពីទិសខាងកើត
ក៏នាំមុខគេរហូតដល់ចំពីលើកន្លែងដែលបុត្រតូចគង់នៅទើបឈប់។
10ពេលឃើញផ្កាយនោះឈប់ដូច្នោះ គេមានអំណរជាខ្លាំង 11ហើយចូលទៅក្នុងផ្ទះ

ឃើញបុត្រតូចនៅជាមួយម៉ារា ជាមាតា គេក៏ក្រាបថ្វាយបង្គំ
រួចបើកប្រអប់យកទ្រព្យរបស់ខ្លួន ជាមាស ជាកំញាន និងជ័រល្វីងទេសថ្វាយដល់បុត្រនោះ។
12បន្ទាប់មក គេក៏វិលត្រឡប់ទៅស្រុករបស់ខ្លួនវិញ តាមផ្លូវមួយផ្សេងទៀត
ដ្បិតព្រះមានព្រះបន្ទូលហាមគេក្នុងយល់សប្តិ មិនឲ្យគេត្រឡប់ទៅជួបហេរ៉ូឌវិញឡើយ។